ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៦១៥ សហវ.ប្រក.គខ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៩

# ប្រកាស

## ស្ដីពី

## ការសម្រុះសម្រួលបទល្មើសគយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងហានិភ័យ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលចំពោះបទល្មើសគយ តាមបញ្ញត្តិមាត្រា ៧៧ នៃច្បាប់ស្តីពីគយ ។ សិទ្ធិសម្រុះសម្រួលនេះ ប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ ។

ការសម្រុះសម្រួលអាចធ្វើទៅបាន តែនៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ចប៉ុណ្ណោះ ។

**ប្រការ ២.-**

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលដូចតទៅ ៖

- ប្រធានទីស្នាក់ការគយ និងរដ្ឋាករមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពី មួយលានប្រាំសែន (១.៥០០.០០០) រៀល
- ប្រធានការិយាល័យ ឬប្រធានសាខាគយ និងរដ្ឋាករ មានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពី បួនលាន (៤.០០០.០០០) រៀល
- អគ្គនាយកគយ និងរដ្ឋាករកម្ពុជា មានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទ ។

**ប្រការ ៣ .-**

អគ្គនាយកគយ និងរដ្ឋាករកម្ពុជាអាចចេញសេចក្តីណែនាំស្តីពីកម្រិតកំណត់និងលក្ខខណ្ឌសម្រាប់សម្រុះសម្រួលបទល្មើសគយ រាប់បញ្ចូលទាំងកម្រិតនៃការពិន័យ និងបញ្ហាពាក់ព័ន្ធផ្សេងទៀត ។

**ប្រការ ៤.-**

បុគ្គលនានាអាចតវ៉ាទៅអគ្គនាយកគយ និងរដ្ឋាករកម្ពុជាក្នុងរយៈពេល សាមសិប (៣០) ថ្ងៃ គិតពីថ្ងៃទទួលនូវកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត ស្របតាមបញ្ញត្តិមាត្រា ៧១ នៃច្បាប់ស្តីពីគយ ។

ក្នុងរយៈពេល សាមសិប ( ៣០ ) ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត បុគ្គលដែលពាក់ព័ន្ធនឹងកំណត់ហេតុទាំងនេះ ត្រូវចូលខ្លួនមកសម្រុះសម្រួល ប្រសិនបើមានបំណងសម្រុះសម្រួលករណីនេះដោយមិនចាំបាច់បញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ។ សិទ្ធិសម្រុះសម្រួល និងការកំណត់ពេលវេលានេះ ត្រូវចែងនៅក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត។

ប្រសិនបើ ក្នុងរយៈពេល កៅសិប(៩០) ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត សេចក្ដីសម្រេចជាផ្លូវការស្ដីពីការសម្រុះសម្រួលទូវបទល្មើសគយមិនអាចធ្វើទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច ។

ទម្រង់នៃសេចក្ដីសម្រេចជាផ្លូវការស្ដីពីការសម្រុះសម្រួលបទល្មើសគយ ត្រូវកំណត់ដោយអគ្គនាយកគយ និងរដ្ឋាករកម្ពុជាហើយត្រូវមានព័ត៌មានដូចតទៅ ៖

- ការយោងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត ដែលជាកម្មវត្ថុនៃការសម្រុះសម្រួល

- កាលបរិច្ឆេទ ហត្ថលេខា នាម តួនាទី និងអាសយដ្ឋានរបស់មន្ត្រីគយមានសមត្ថកិច្ចដែលទទួលខុសត្រូវសម្រុះសម្រួលបទល្មើស

- កាលបរិច្ឆេទ ហត្ថលេខា នាម តួនាទី និងអាសយដ្ឋានរបស់បុគ្គលដែលជាកម្មវត្ថុនៃបទល្មើសគយ

- និមុត្តិជានាដែលត្រូវបានតម្កល់ដោយបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន

- សេចក្ដីលម្អិតនៃកិច្ចសម្រុះសម្រួលដែលបានព្រមព្រៀង ព្រមទាំងកម្រិតកំណត់ និងលក្ខខណ្ឌនានាសម្រាប់អនុវត្តសេចក្ដីសម្រេចជាផ្លូវការនេះ

- សេចក្ដីសម្រេចជាផ្លូវការស្ដីពីការសម្រុះសម្រួលបទល្មើសគយនេះ ត្រូវធ្វើឡើងជាបី (៣) ច្បាប់ ដែល ពីរ (២) ច្បាប់ត្រូវរក្សាទុកដោយរដ្ឋបាលគយ ហើយ មួយ (១) ច្បាប់ ផ្សេងទៀតត្រូវផ្ដល់ជូនបុគ្គលពាក់ព័ន្ធ ។

**ប្រការ ៥.-**

បុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមកម្រិតកំណត់ និងលក្ខខណ្ឌនានានៃសេចក្ដីសម្រេចផ្លូវការស្ដីពីការសម្រុះសម្រួលបទល្មើសគយ រាប់បញ្ចូលទាំងការបង់ប្រាក់ពិន័យ ពន្ធ និងអាករដែលត្រូវជាប់ និងកាតព្វកិច្ចផ្សេងទៀតដែលមានចែងក្នុងសេចក្ដីសម្រេច ក្នុងរយៈពេល កៅសិប (៩០) ថ្ងៃ គិតពីកាលបរិច្ឆេទនៃសេចក្ដីសម្រេច ។ ប្រសិនបើបុគ្គលពាក់ព័ន្ធខកខានអនុវត្តតាមកម្រិតកំណត់ និងលក្ខខណ្ឌនានានៃសេចក្ដីសម្រេចក្នុងរយៈពេលកំណត់នេះ ទំនិញដែលជាកម្មវត្ថុនៃសេចក្ដីសម្រេចផ្លូវការនេះត្រូវចាត់ទុកជាទំនិញគ្មានការទាមទារតាមបញ្ញត្តិមាត្រា ៥៤ និងមាត្រា ៥៥ នៃច្បាប់ស្ដីពីគយ ។ កម្រិតកំណត់ និងលក្ខខណ្ឌនៃប្រការនេះត្រូវចែងក្នុងសេចក្ដីសម្រេចផ្លូវការ ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះ ឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ